Reçu le 7-4-52
INDOCHINE FRANÇAISE RÉGIE DU DÉPÔT LÉGAL
B-7
B. 79-841 D-37
N° 29

ច្បាប់ទី ១

វិធីបង្រៀនអក្សរសាស្ត្រឲ្យចេះឆាប់ទាន់សម័យ

# កុមារដ្ឋាន
# ម៉ម-សុទ្ធ.១៩៥២

# MÉTHODE MODERNE ET RAPIDE

POUR L'ENSEIGNEMENT DU CAMBODGIEN DU 1er DEGRE

PREMIER LIVRET

**COURS ENFANTIN**

ទុកសិទ្ធិ

បោះពុម្ពលើកទី ១

ចំនួន ៥ ០០០ ច្បាប់

ម៉ម - សុទ្ធ

ស្នាក្តីសាលាខ្មែរ ផ្ទះលេខ ៣១០

ផ្លូវវេរដង់ ភ្នំពេញ

ARCHIVES NATIONALES
DÉPÔT LÉGAL
ARCHIVES NATIONALES
COTE

# នមោ (១)

## ពុទ្ធាយ សិទ្ធំ

ក្មេងណាៗ ស្វាហ៍អាយុវែង  ច្បាស់ទែងដូចផ្ទះកញ្ចក់ថ្មី
អ្នករៀនតែងបានធ្វើមន្ត្រី  ទីងធ្វើសេដ្ឋីស្មើគ្រប់ប្រាណ ៗ
ហេតុនោះមុខរៀនរបៀនចំ  ត្រូវខំសិក្សាឲ្យក្លាហាន
ចូរដឹងត្រូវប្រឹងកុំឈប់ខាន  គ្រូប្រាប់ប៉ុន្មានអានឲ្យច្បាស់ ៗ
នឹងឡើងថ្នាក់ខ្ពស់ឈ្មោះបានល្បី  ឃើញហេតុបើទាំងក្មេងចាស់
គ្រូអ្នកស្មោះសរសេរខ្ញុំណាស់  អ្នកនឹងផុតខ្មាស់ក្មេងជិតក្បែរ ៗ
ទេព្ដារក្សាគតផែនដី  ជួយលើកពាសីឲ្យពូកែ
ឈរចាំទ្រទ្រង់វង្សកូនខ្មែរ  ឲ្យថែរក្សាមហាជន ៗ
ឲ្យថែរក្សាខេមរជាតិ  ឲ្យឃ្លាតផុតមុខពីទុក្ខធ្ងន់
ខ្ញុំងបាំងមុខខ្មែរបែរជាទន់  ត្រឡប់ចងពន្ធមេត្រីវិញ ៗ

មន្តគាថានេះបើអ្នកសូត្រ ៣ ចប់ហើយដេកឲ្យស្រួល នោះអ្នកនឹងបានដំណើងតាមទេព្ដារក្សាស្រុក ពន្យល់អ្នកនៅពេលដែលអ្នកមានទុក្ខធុរៈ អឺម្យ៉ាងៗ ៗ

"រក្សាសិទ្ធិ"

---

១ នមោ: ហៅនាក់មោ សេចក្ដីថា បន្ទន់កាយ, វាចា, នឹងចិត្តថ្វាយបង្គំ ។
ពុទ្ធាយ ហៅពុទធាយាក់ សេចក្ដីថាចំពោះព្រះពុទ្ធ ។
សិទ្ធំ: ហៅសិទថាំង សេចក្ដីថា សុំឲ្យបានសំរេចដោយការបេះដឹង ។

វិធីសិក្សា-កុមារដ្ឋាននេះ ខ្ញុំបានព្យាយាមជានិច្ច អំពីរះរកផ្លូវពក៣ ឲ្យក្មេងរៀនឆាប់ចេះ ។ ខ្ញុំបានបង្រៀនខ្លួនឯងពិសោធន៍មើល, បានឃើញច្បាស់ក្មេងរៀនរហ័ស ចំពោះតែគំនូរណាដែលមានពាក្យជូននិយាយអមនឹងរូបគំនូរនោះៗ សិស្សអាចមើលរប់ ៗ ជាបទកាកគតិបានដោយងាយ គឺ ជាដំណើរមួយដ៏សមល្មមធ្វើឲ្យក្មេងពេញចិត្ត នឹងមើលពាក្យជូនតាមរូបគំនូរនោះ ដោយមានសំរើបពីចិត្តឯងថែមទៀត ។ ឃើញមានប្រយោជន៍ជាងពាក្យប្រកបតាមពួកអក្សរខ្វី ៗ ហេតុដូច្នេះបានជាខ្ញុំធ្វើឲ្យមានពាក្យជូនគ្រប់តែរូបគំនូរថែមលើសមុនជាច្រើន ជាជំនួសពាក្យប្រកបខ្វី ៗ ទាំងនោះវិញ ។ សូមលោកគ្រូបង្រៀនជួយសម្រួលតាមការណ៍គួរចំពោះសិស្សដែលមានស្មារតីផ្សេង ៗ គ្នា ។

ខ្ញុំបានថតអក្សរដៃ ដាក់គ្រប់តួអក្សរដែលត្រូវបង្រៀនប្រកប នឹងដាក់គ្រប់តួអក្សរដែលត្រូវបង្ហាត់អក្សរផ្ចង់ ធ្វើឲ្យកូនសិស្សងាយរៀនសរសេរតាម ឲ្យបានសមរម្យតាមក្បួនបង្រៀនប្រទេសនានា ដែលគេបានធ្វើរួចហើយ ។

ម៉ម - សុទ្ធ

មេធាវី ផ្ទះលេខ ៣១០ វិថីវេរដង

ក្រុងភ្នំពេញ

នមស្សការ

# នមោ ពុទ្ធាយ សិទ្ធំ(១)

ស្រៈ ១៨ តួ

អអា ឥឦ ឧឩ ឫឬ ឭឮ ឯឰ ឱឲ អុំអំអាំអះ ។

ព្យញ្ជនៈ ៣៣ តួ (ឥតជើង)

កខគឃង, ចឆជឈញ, ដឋឌឍណ,

តថទធន, បផពភម, យរលវសហឡអំ(២)

---

(១) នមោ ពុទ្ធាយ សិទ្ធំ អក្សរ ៧ តួនេះជាពាក្យនមស្សការ សម្រាប់ឲ្យអ្នករៀនអក្សរសូត្ររំឭកគុណព្រះពុទ្ធជាមុន; ត្រូវសូត្រថា: នៈមោ ពុទ្ធាយៈ សិទ្ធំង ។ ពាក្យនេះបើប្រែជាខ្មែរថា: “នមោ សូមនមស្សការក្រាបថ្វាយបង្គំ ពុទ្ធាយ ចំពោះព្រះពុទ្ធ សិទ្ធំ សូមឲ្យបានសំរេចដោយការចេះដឹង” ។

(២) តួអក្សរ “អ័ង” នេះហៅថា “និគ្គហិត” ឬ “ដំលើ” សម្រាប់ប្រើដាក់ពីខាងលើអក្សរដែលគួរដាក់លើបាន ។ យើងត្រូវបង្រៀនសិស្សឲ្យសរសេរត្រឹមតែដំ “o” ប៉ុណ្ណោះ គឺឲ្យសរសេរ (ឮ o) ។

# នមោ

# ពុ ទ្ធា យ សិ ទ្ធំ

# អ អា ឥ ឦ ឧ ឩ

# ឫ ឬ ឭ ឮ ឯ ឰ ឱ

# ឳ អំ អុំ អាំ អះ ។

អក្សរតួមូលប្លែកគ្នាពីតួឈរតែ ៧ តួគឺ

# គ ង ជ ឈ ញ

# ល វ

# អក្សរតួខម

ក្ក ខ្ខ គ្គ ឃ្ឃ ង្ង

ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ

ដ្ដ ឋ្ឋ ឌ្ឌ ឍ្ឍ ណ្ណ

ត្ត ថ្ថ ទ្ទ ធ្ធ ន្ន

ប្ប ផ្ផ ព្ព ភ្ភ ម្ម

យ្យ រ្រ ល្ល វ្វ ស្ស

ហ្ហ ឡ អំ

## ស្រៈមាន ៣ យ៉ាង

ស្រៈសម្រាប់ប្រើចំពោះភាសាខ្មែរយើង, បើនិយាយតាមដំណើរ ដែលផ្សេងគ្នា, មាន ៣ យ៉ាងគឺ ស្រៈពេញតួ, ស្រៈផ្សំ, ស្រៈនិស្ស័យ ។ ស្រៈដែលសរសេរពេញតួស្រេច មិនបាច់អាស្រ័យនឹងអក្សរផងគ្នា ហៅថាស្រៈពេញតួ ។ ស្រៈដែលមានរូបពេញតួស្រេចហើយ ថែមផ្សំជាមួយនឹងស្រៈផងគ្នា, ជាមួយនឹងនិគ្គហិត ឬវិសជ្ជនីយ គឺរះមុខ "ះ" នេះផងទៀត, ហៅថាស្រៈផ្សំ ។ ស្រៈដែលមានរូបមិនពេញតួ សម្រាប់ប្រើផ្សំនឹងស្រៈ "អ" ឬផ្សំនឹងព្យញ្ជន ហៅថាស្រៈនិស្ស័យ ។

---

### ស្រៈពេញតួមាន ១៤ តួគឺ

អអា ឥឦ ឧឩ ឫឬ ឭឮ ឯឰ ឱឳ

### ស្រៈផ្សំ

អ អា អិ អី អឹ អឺ អុ អូ អួ អើ អឿ អៀ អេ អែ អៃ
អោ អៅ អុំ អំ អាំ អះ ។

### ស្រៈនិស្ស័យមាន ២១ តួគឺ

ı ា ិ ី ឹ ឺ ុ ូ ួ ើ –ឿ –ៀ េ–
ែ– ៃ– –ោ –ៅ ុំ ំ –ាំ ះ ។

---

## សំឡេងស្រៈនិស្ស័យ

ស្រៈនិស្ស័យមានសូរសំឡេង ២ យ៉ាងគឺ សំឡេងតូច (អឃោសៈ) សំឡេងធំ (ឃោសៈ) ។ កាលណាបើស្រៈនិស្ស័យផ្សំជាមួយនឹងអក្សរ ដែលមានសូរសំឡេងតូច, ក៏មានសំឡេងតូចតាមអក្សរនោះ(១) ។ បើផ្សំជាមួយនឹងអក្សរ ដែលមានសូរសំឡេងធំ ក៏មានសំឡេងធំតាមអក្សរ(២) នោះ ។

អក្សរសំឡេងតូចមាន ២៤ តួគឺ:

ក ខ, ច ឆ, ដ ឋ, ណ,(២) ត ថ, ប ផ, ង៉, ញ៉ ន៉ ប៉, ម៉, យ៉, រ៉ ល៉, វ៉, ស ហ ឡ អ ។

អក្សរសំឡេងធំមាន ២២ តួគឺ :

គ ឃ ង, ជ ឈ ញ, ឌ ឍ, ទ ធ ន, ព ភ ម, យ រ, ល វ ប៊, ស៊, ហ៊, អ៊ ។

---

(១) "សញ្ញា, បញ្ញា, បន្ទា" ឲ្យថា "សញ្ញ៉ា, បញ្ញ៉ា, បន្ទ៉ា," មិនត្រូវមាន មូសិកទន្តទេ ។

(២) អក្សរ "ណ" នេះ បើពាក្យតែមួយមាត់ ដែលមានអក្សរសំឡេងធំនៅពីខាងដើម បន្ទាប់ខ្លួន, ក៏ប្រែជាមានសំឡេងធំទៅវិញ ដូចពាក្យថា "ធរណី, ព្រះធរណី, បវេណី អរណី" ឲ្យថា "ធរនី, បវេនី, អរនី" ។

## អក្សរសម្លាប់

អក្សរដែលមានសំឡេងធំ បំបែរឲ្យមានសំឡេងតូចដោយយកក្បៀស ២ " " ដែលហៅថា មូសិកទន្ត "ធ្មេញកណ្ដុរ" នេះមកគូសពីលើ, ហៅថាអក្សរសម្លាប់ ។ ដើម្បីឲ្យប្រែសូរសំឡេងពីធំទៅតូចបាន នោះមានតែ ៨ តួគឺ ង ញ ន ម, យ រ ល វ ជា ង៉ ញ៉ ន៉ (១) ម៉; យ៉ រ៉ ល៉ (២) វ៉ ។ មានតួ "ប" មួយទៀតជាអក្សរសំឡេងតូច សម្លាប់បំបែរសំឡេងឲ្យតូចផ្សេងទៅវិញ "ប៉" ។ សម្លាប់បំបែរសំឡេងឲ្យធំផ្សេងទៅវិញ "ប៊" ។ ឯរបៀបសម្លាប់អក្សរសំឡេងតូច ៤ តួ ឲ្យទៅជាសំឡេងធំគឺ: ប, ស, ហ, អ ទៅជា ប៊ ស៊, ហ៊, អ៊ ។

---

១ – ២ អក្សរ ន, ល នេះ ពិតជាមានទំនងឲ្យសម្លាប់បានមែន តែមានអក្សរ "ណ, ឡ" ប្រើជាជំនួស បានដោយអន្លើ ។

## ផ្ដើមបង្រៀនភាគទី ១

គឺចាប់ផ្ដើមឲ្យសិស្សរៀនបំបែកជាដំបូង ដំណើរមួយពួកប្រាំតួហើយ បង្រៀនប្រកបបណ្ដើរៗ តែតួដែលបានរៀនរួចហើយដូចមានខាងក្រោមៈ

**ក ខ គ ឃ ង**

១– ក កា កិ កី កឹ កឺ កុ កូ កួ កើ កឿ កៀ កេ
កែ កៃ កោ កៅ កុំ កំ កាំ កះ ៖

កក កក់ កោក កាក

២– ខ ខា ខិ ខី ខឹ ខឺ ខុ ខូ ខួ ខើ ខឿ ខៀ ខេ
ខែ ខៃ ខោ ខៅ ខុំ ខំ ខាំ ខះ

ខក ខក់ ខោក ខាក

៣– គ គា គិ គី គឹ គឺ គុ គូ គួ គើ គឿ គៀ គេ
គែ គៃ គោ គៅ គុំ គំ គាំ គះ

គគីរ គរគោក

៤- យ យា យិ យី យឹ យឺ យុ យូ យួ យើ យឿ
យៀ យេ យែ យៃ យោ យៅ យុំ យំ យាំ យះ

*យោរយៅ យាំងយា*

៥- ង ងា ងិ ងី ងឹ ងឺ ងុ ងូ ងួ ងើ ងឿ ងៀ ងេ
ងែ ងៃ ងោ ងៅ ងុំ ងំ ងាំ ងះ

*ងេងើ ងាក ងោក*

*កុំកោកកាក កុំខោកខាក*

| ប ផ ជ ឈ ញ |
|---|

៦- ប បា បិ បី បឹ បឺ បុ បូ បួ បើ បឿ បៀ បេ
បែ បៃ បោ បៅ បុំ បំ បាំ បះ

*បូក បក បាក់បេញ*

៧- ផ ផា ផិ ផី ផឹ ផឺ ផុ ផូ ផួ ផើ ផឿ ផៀ ផេ
ផែ ផៃ ផោ ផៅ ផុំ ផំ ផាំ ផះ

*ផា ផៅ ផែក ផេរ*

៨- ដ ដា ដិ ដី ដឹ ដឺ ដុ ដូ ដួ ដើ ដឿ ដៀ ដេ
ដែ ដៃ ដោ ដៅ ដុំ ដំ ដាំ ដះ

ដដែក ដោក ដាំ

៩- ឈ ឈា ឈិ ឈី ឈឹ ឈឺ ឈុ ឈូ ឈួ
ឈើ ឈឿ ឈៀ ឈេ ឈែ ឈៃ ឈោ ឈៅ
ឈុំ ឈំ ឈាំ ឈះ

ឈរ ឈោង ឈូក ឈុំ

១០- ញ ញា ញិ ញី ញឹ ញឺ ញុ ញូ ញួ ញើ
ញឿ ញៀ ញេ ញែ ញៃ ញោ ញៅ ញុំ ញំ
ញាំ ញះ

ញញាក់ ញញួរ

ដាងដា តាបែងកា កុំឆាតៅតេ

## ដ ឋ ឌ ឍ ណ

១១– ដ ដា ដិ ដី ដឹ ដឺ ដុ ដូ ដួ ដើ ដឿ ដៀ ដេ
ដែ ដៃ ដោ ដៅ ដុំ ដំ ដាំ ដះ

*ដិក ដាក់ ដឹក ដែក*

១២ – ឋ ឋា ឋិ ឋី ..................... ឋះ

*គ្មានពាក្យប្រើ*

១៣ – ឌ ឌា ឌិ ឌី ..................... ឌះ

*ឌី ឌឿ*

១៤ – ឍ ឍា ឍិ ឍី ..................... ឍះ

*គ្មានពាក្យប្រើ*

១៥ – ណ ណា ណិ ណី ណឹ ណឺ ណុ ណូ ណួ
ណើ ណឿ ណៀ ណេ ណែ ណៃ ណោ ណៅ
ណុំ ណំ ណាំ ណះ

*ណូស់ ណាស់ ណោស់ ណាស់*

ចំណាំ ចែកចំណី កុំកំណាញ់

## ត ថ ទ ធ ន

១៦ – ត តា តិ តី តឹ តឺ តុ តូ តួ តើ តឿ តៀ តេ
តែ តៃ តោ តៅ តុំ តំ តាំ តះ

*តាក់តែង តូច តាច*

១៧ – ថ ថា ថិ ថី ថឹ ថឺ ថុ ថូ ថួ ថើ ថឿ ថៀ ថេ
ថែ ថៃ ថោ ថៅ ថុំ ថំ ថាំ ថះ

*ថា ថាស ថិត ថេរ*

១៨ – ទ ទា ទិ ទី ទឹ ទឺ ទុ ទូ ទួ ទើ ទឿ ទៀ ទេ
ទែ ទៃ ទោ ទៅ ទុំ ទំ ទាំ ទះ

*ទាញ ទន់ ទាក់ ទង*

១៩ – ធ ធា ធិ ធី ធឹ ធឺ ធុ ធូ ធួ ធើ ធឿ ធៀ ធេ
ធែ ធៃ ធោ ធៅ ធុំ ធំ ធាំ ធះ

*ធំ ធាត់*

*ចៅកែនដដែក ចង់ទារៀនំនៃក ពុំទាន់ដឹងការ*

២០ – ន នា និ នី នឹ នឺ នុ នូ នួ នើ នឿ នៀ នេ
នែ នៃ នោ នៅ នុំ នំ នាំ នះ

*នឹង នួន នឹក នាង*

## ប ផ ព ភ ម

២១ – ប បា បិ បី បឹ បឺ បុ បូ បួ បើ បឿ បៀ បេ
បែ បៃ បោ បៅ បុំ បំ បាំ បះ

*បោក បែក បែន បុក*

២២ – ផ ផា ផិ ផី ផឹ ផឺ ផុ ផូ ផួ ផើ ផឿ ផៀ ផេ
ផែ ផៃ ផោ ផៅ ផុំ ផំ ផាំ ផះ

*ផូរ ផង់ ផុត ផែន*

២៣ – ព ពា ពិ ពី ពឹ ពឺ ពុ ពូ ពួ ពើ ពឿ ពៀ ពេ
ពែ ពៃ ពោ ពៅ ពុំ ពំ ពាំ ពះ

*ពើត ពើង ពាន់ ពោក*

២៤– ភ ភា ភិ ភី ភឹ ភឺ ភុ ភូ ភួ ភើ ភឿ ភៀ ភេ
ភែ ភៃ ភោ ភៅ ភុំ ភំ ភាំ ភះ

*ភិន ភាគ ភុំ ភៀន*

២៥– ម មា មិ មី មឹ មឺ មុ មូ មួ មើ មឿ មៀ មេ
មែ មៃ មោ មៅ មុំ មំ មាំ មះ

*មក មុន មុត ម៉ែន*

*កុំដើរទៅណាបើឃើញខាតការកូនកុំដើរដិត។*

| យរលវសហឡអ |
|---|

២៦– យ យា យិ យី យឹ យឺ យុ យូ យួ យើ យឿ យៀ
យេ យែ យៃ យោ យៅ យុំ យំ យាំ យះ

*យាយ យើង យឺត យោង*

២៧– រ រា រិ រី រឹ រឺ រុ រូ រួ រើ រឿ រៀ រេ រែ រៃ
រោ រៅ រុំ រំ រាំ រះ

*រួស រាន់ រីក រាយ*

២៨– ល លា លិ លី លឹ លឺ លុ លូ លួ លើ លឿ លៀ
លេ លែ លៃ លោ លៅ លុំ លំ លាំ លះ

*លួក លាស់ លឿន លន់*

២៩– រ រា រិ រី រឹ រឺ រុ រូ រួ រើ រឿ រៀ រេ រែ រៃ រោ
រៅ រុំ រំ រាំ រះ

*រាល រើស រាស់ រង់*

៣០– ស សា សិ សី សឹ សឺ សុ សូ សួ សើ សឿ
សៀ សេ សែ សៃ សោ សៅ សុំ សំ សាំ សះ

*សុិ សង់ សាមសិប*

៣១– ហ ហា ហិ ហី ហឹ ហឺ ហុ ហូ ហួ ហើ ហឿ
ហៀ ហេ ហែ ហៃ ហោ ហៅ ហុំ ហំ ហាំ ហះ

*ហួង ហែង ហោះ ហើរ*

៣២– ឡ ឡា ឡិ ឡី ឡឹ ឡឺ ឡុ ឡូ ឡួ
ឡើ..........(គ្មាន)..........ឡះ

*ឡេះ ឡោះ ឡូ ឡា*

# ៣៣– អ អា អិ អី អឹ អឺ អុ អូ អួ អើ អឿ អៀ អេ អែ អៃ អោ អៅ អុំ អំ អាំ អះ

*ទើត ទើម អង់ អាច*

## អក្សរផ្ញើជើង

អក្សរដែលផ្សំជាមួយនឹងជើងអក្សរឯទៀតផ្សេង មានសំឡេងលាន់ឮតាំង ២ ពីលើចុះមកក្រោម គឺត្រូវថាពីតួលើចុះមកជើងខាងក្រោម ឲ្យឮស្មូរសំឡេងផ្គាប់ផ្គួបគ្នាតែមួយ ហៅថាអក្សរផ្ញើជើង ។ ប៉ុន្តែត្រង់ជើងអក្សរ ៨ តួគឺ ង ញ ណ ម យ រ ល វ នេះ បើយកផ្ញើនឹងតួអក្សរមានសំឡេងតូច ក៏មានសំឡេងតូចតាមតួលើ ដូចជា ក្ង ខ្ញ ប្ន ឆ្ម ក្យ ត្រ ង្ល ស្វ ជាដើម មិនត្រូវសម្គាល់ទេ ។ អក្សរផ្ញើជើងដូចរបៀបតទៅនេះ ៖

ក្ង ក្ដ ក្ន ក្ប ក្ម ក្យ ក្ល ក្វ ក្ស ក្ស ។ ខ្ង ខ្ច ខ្ញ ខ្ទ ខ្ត ខ្ន
ខ្យ ខ្ល ខ្វ ខ្ស ។ គ្ន គ្ម គ្យ (គ្ល) គ្វ ។ ឃ្ន ឃ្ម ឃ្ល ឃ្វ ។
ច្ន ច្ប ។ ឆ្ក ឆ្វ ឆ្ន ឆ្ម ឆ្វ ឆ្ស ។ (ជ្ញ) ជ្វ ។ ឈ្វ ឈ្ន
ឈ្ម ឈ្វ ។ ដ្ប ។ ត្ន ត្ប (ត្យ ត្វ ត្ស) ត្ស ។ ថ្ក ថ្គ ថ្វ
ថ្ន (ថ្ប) ថ្ដ ថ្ម ថ្ល ថ្វ ។ ទ្យ ទ្វ ។ ផ្វ ផ្ន ផ្ម ផ្យ ផ្ល ផ្វ ។

ប្ដ (ប្យ) ប្ល ប្ប ។ ផ្ក ផ្គ ផ្ង ផ្រ ផ្ដ ផ្ត[១] ផ្ញ ផ្ន ផ្យ ផ្ល ផ្ស ផ្អ ។ ព្ន ព្យ ។ ភ្វ ភ្ជ ភ្រ ភ្ន ភ្យ ភ្ល ។ ម្ក ម្ង ម្ជ ម្ន ម្ទ ម៉្យ ម្ល ម៉្ល ម្យ ម្ហ ម្អ ។ ល្គ ល្វ ល្ប ល្ត (ល្យ) ល្វ ល្ហ ល្អ ។ ស្ក ស្គ ស្វ ស្រ ស្ដ ស្ត[២] ស្ញ ស្ន ស្ប ស្ត ស្ម ស្យ ស្ល ស្វ ស្អ ។ ហ្ន ហ្ម ហ្វ[៣] ។

## អក្សរក្រភាត់

អក្សរផ្ញើជើងនោះឯង ដោយសារយកជើង រ « ្រ » នេះមកផ្ញើ មានសណ្ឋានប្រហែលដូចគេក្រវាត់ព័ទ្ធពីក្រៅ ក៏បែរជាហៅថា អក្សរក្រវាត់ទៅវិញ ។ អក្សរក្រវាត់នោះដូចមានរបៀបខាងក្រោមនេះ ៖

ក្រ គ្រ ប្រ ជ្រ ត្រ ទ្រ ឆ្រ ប្រ ព្រ ម្រ ស្រ[៤]

---

១ មួយជាជើង ង មួយជាជើង ត ។ ២ មួយជាជើង ដ មួយជាជើង ត ។ ៣–៤ អក្សរផ្ញើជើង ក្រភាត់ប៉ុណ្ណោះ សម្រាប់ប្រើចំពោះតែពាក្យទាំងឡាយដែលធ្លាប់ប្រើរៀងមក ប៉ុន្តែមិនទាន់គ្រប់គ្រាន់ដល់ការសរសេរពាក្យចំណូលថ្មីនៅឡើយ ។ បើយើងត្រូវការប្រើ គួរបន្ថែមអក្សរផ្ញើជើង ក្រភាត់ខ្លះឡើងទៀត ដូចយ៉ាងអក្សរ គ្វ ទ្រ ហ្វ ហ្ស ហ្ស៊ ជាដើម សម្រាប់សរសេរ ឈ្មោះស្រុក ទីជំបន់ ឈ្មោះមនុស្ស ឬឈ្មោះវត្ថុអ្វីមួយ ដែលជាសំដីចំណូលថ្មី ក្នុងសម័យនេះ ដូចពាក្យថា ស្រុកអាហ្វ្រិក សាលាហ្វ្រង់ស្វ័រ ហ្វូង់ ប្រាក់ប៉ុតហ្ស៊ែ ហ្ស៊ង់ប្អូន ហ្សាន ជាមិត្រសំឡាញ់គ្នានឹងអង់ទ្រេ ជាដើម ឲ្យតួអក្សរផ្ញើជើងក៏សឹងតែបាន តាមខ្លួនដល់ការសរសេរបានថាកើត ។

## ហាត់មើលរបៀបផ្ញើដើង

*បទកាកគតិ*

ក្ដាម គ្រោង ម្នី ម្នា, មុជ ក្នុង គង្គា, ឃើញ ក្ដាន់ មក ក្បែរ, ខ្លា ខ្មៅ មាត់ ខ្លី, អាង ខ្លាំង ពូ កែ, ទន្សាយ ខ្លាប ផ្ដែ, រត់ ទៅ ជិត ខ្លា ។ ផ្លែ ភ្លៅ នៅ ភ្នក់, ឆ្មា ឈ្មោល ដេក លក់, កណ្ដុរ ផ្លេ ផ្លា, ផ្លង ទៅ ផ្លង មក, គ្មាន គិត អាត្មា, បាន ជា អាហារ, សត្វ ឆ្មា ពុំ ខាន ។ ស្វា ស៊ី ផ្លែ ល្វា, ជួប ជុំ គ្នី គ្នា, ក្នុង ព្រៃ ស្មសាន, ខ្លា ស្ទុម មក ជិត, គិត ស៊ី ឲ្យ បាន, ខ្លា បង្ហាញ ប្រាណ, ឲ្យ ស្វា ឃើញ ច្បាស់ ។ មារ យាទ សត្វ ស្វា, លុះ បាន ឃើញ ខ្លា, បេះ ដៃ ស្វា ខ្លះ, ទម្លាក់ ឲ្យ ស៊ី, មួយ ពីរ ឥត ខ្វះ, តាម បណ្ដាំ ចាស់, ថា កុំ ធ្វើ ជួប ស្វា ។

### ផ្ដើមបង្ហាត់ភាគ ទី ២

*គិតឲ្យបានចម្រើន ៣ យ៉ាង ១- ហាត់មើល ២- ឲ្យចេះពាក្យសុភាសិត, ៣- ឲ្យមានសម្រើបចិត្តនឹងមើលពីខ្លួនឯង ចាប់ផ្ដើមពីអក្សរ ( ក ) តទៅ ៗ*



ក្ដាម

ស្ដីពីសត្វក្ដាម ស៊ីច្រើនប្រឆាម ពុំសូវ
ពិសា បើក្ដាមសមុទ្រ គេច្រើនត្រូវការ
ធ្វើជាអាហារ ដោយសារក្ដាមប្រៃ ។



ក្របី

រៀងសត្វក្របី គេភ្ជួររាស់ដី ធ្វើស្រែ
ចំការ ខាងក-សិ-កម្ម(១) បានគ្រប់អា-ត្មា
ក្របីនេះណា គួរអ្នកសួនគ្រង ។

(១) កសិកម្ម "ការភ្ជួររាស់"



ក្ងានដេញកូនក្មេង

កវែង ក្ងាន បុកវា កុំជាន គ្រាន់បើ
ជាងទា ចំពុះកំប៉ែត ជើងជាប់ដូចគ្នា
ចិត្តកាចពុំជា ដេញហួរកូនក្មេង ។

---

យាយតារីករាយ ឃើញកូនចៅឆាយ
រៀនចេះរហ័ស ដើរលឿនរហូត តាមដាន
ចាស់ៗ ម៉ែឪអរណាស់ ឃើញចេះដូចចិត្ត ។



កណ្ដុរ

រៀនសត្វកណ្ដុរ ចិត្តវាជាចោរ អាក្រក់
ពេកក្ដាត់ ព្រែហូលថ្មីចាស់ វាលួចច្រិប
កាត់ គេទុកជាសត្វ អាក្រក់ពេកក្រៃ ។

កាលកូនមានបុណ្យ ត្រូវរៀនដោះកុន ឲ្យរូបក្ដីស្អប់ រកបានអ្នកបេះ កុំបោលប្រសប់ ហស់ហាបេះដប់ ពុំស្មើ ប្រសប់មួយ ។



ក្ងោក

ក្ងោក បក្សា រូប ល្អ អស្ចារ្យ លើសលុប
សត្វ ដទៃ ស្លាប វា ភ្លឺ ផ្លេក មានពណ៌បៃ
តង ជាន់ចាស់ ធ្វើស្នង សូនអាសធ្វើរូប។

អក្សរផ្ចង់

កូនកាន់ការកើត ទើបបានគង់គេ



ខ្លា

សត្វខ្លានេះនៃ រស់នៅក្នុងព្រៃ ស៊ីជា
អាហារ សាច់សត្វនានា ចំអែតអាត្មា
កំណាចអស្ចារ្យ លើសលុបអស់សត្វ ។
ទោះមនុស្សក្ដីណា ចូលព្រៃព្រឹក្សា តែង
តែប្រយ័ត្ន ដោយខ្លាចជួបខ្លា នោះណា
ជាសត្វ កំណាចពេកក្ដាត់ ភិតភ័យ
គ្រប់គ្នា ។

អក្សរផ្ចង់

ខិល ខូច ខ្ជូរ ខាប់ ខិជខុស ខាត ខាន



សត្វខ្លែង
បក្សហើរ
រកអាហារ
ឆក់ឆាប
កូនមាន់

កាលឆក់ឆាបបាន ស្មានថាខ្លួនគ្រាន់ កាល
ម្ចាស់គេទាន់ ជើងជាប់អន្ទាក់ ។



សត្វគោគួរគាប់
សត្វគោគេរាប់-
អានគ្រប់អាត្មា

ប៉ែកកសិកម្ម ប្រើជាធម្មតា ធ្វើស្រែចំការ
សត្វគោនេះឯង ។



គីង្គក់

គីង្គក់ គរគោក ជាសត្វ ស្មោកគ្រោក
ស្បែកវា គគ្រាត ពណ៌វា គគ្រិច កើតស្រែង
មួយជាតិ ពេលយប់រាត្រី វាចេញរកស៊ី



សត្វទុកនេះនៃ ពេលថ្ងៃពួនព្រៃ
រកស៊ីតែយប់ ភ្នែកឃើញដេញ
ចឹក មិនចេះឈរឈប់ រកស៊ី
ពេលយប់ ចំអែតអាត្មា ។

អក្សរផ្ចង់

គុណា គាប់ គង្គា គរគោក



ឃ្មុំ

ស្ដីពីសត្វឃ្មុំ ប្រមូលគ្នាជុំ ធ្វើជាសំបុក សត្វមានសាមគ្គី[១] ចេះរកស៊ីចុក ការពារយកសុខ នៃក្រុមគ្រួសារ ។ បើមនុស្សនៅនា ចេះចងបាច់គ្នា បានត្រប់អាត្មា ការពារ ភូមិស្រុក កុំស្ដាយជីវា ទើបហៅស្នេហា ដល់ជាតិមាតុភូមិ ។

អក្សរផ្ចង់

ឃុប ឃិត ឃោរឃៅ ឃុក ឃាក់

១– សាមគ្គី “ព្រមព្រៀងគ្នា, ចងបាច់គ្នា, រួមគ្នា.”



ងូតទឹក

ងូតទឹកក្នុងពាង ចង់ស្អាតត្រូវលាងឲ្យជ្រះ
កាយា ចាំត្រៀមប្រដាប់ សម្រាប់ប្រើការ
បានគ្រប់អាត្មា មានពាងគ្រប់ផ្ទះ ។

ងេងងោងងុយងោក ដូចស្រវឹងដោក
ដើរឆ្ងាយពុំបាន ងងឹតមុខស្លុង ត្រដាក់
អស់ប្រាណប្រញាប់កុំខាន ហៅគេឲ្យជួយ ។

អក្សរផ្ចង់

ងេងើ ងេងងោង ងុយងោក



៣៨

ប្រយោជន៍ពីចាន ជាគ្រឿងបំណាន សំរាប់ប្រើការ មានច្រើនបែបយ៉ាង ខាងដាក់អាហារ គេឲ្យឈ្មោះថា ចានក្បានតូចធំ ។



ចិញ្ចៀន

ចិញ្ចៀនត្បូងឆ្នៃ[1] ពាក់នៅម្រាមដៃ ជាគ្រឿងសំអាង ស៊ិកតាមនាងដៃ មានច្រើនបែបយ៉ាង គេពាក់តែម្ខាង ដៃឆ្វេងនោះនៃ ។

អក្សរផ្ចង់

ចែក ចាយ ចៀស ចេញ ចោមចាប់

១ ឆ្នៃ "យកពេជ្រដែលរើសបានមក ហើយយកទៅប្រស៊ុំឲ្យស្អាត ដោយគ្រឿងក្រឡឹង" ។



ឆ័ត្រ

*ឆត្របាំងភ្លៀងថ្ងៃ មានថោកមានថ្លៃ*
*ការពារអាត្មា ប្រដាប់មួយមុខ ទុកគ្រាន់ប្រើ*
*ការ បើថែរក្សា ប្រើការបានយូរ*

ឆោមឆើតឆាយា ដល់អស់កុមារ ប្រឹងរៀនវិជ្ជា និស្សិត បំណាន បានបេះប្រើនគ្នា គ្រាន់បានការពារ ព្រះរាជអាណាចក្រ ។



ឆ្កែ

បំណែកសត្វឆ្កែ ជាសត្វពូកែ ចាំផ្ទះសម្បែង បើមានមនុស្សប្លែក វាព្រុសកំហែង វាខាំដាច់កែង ហូរឈាមស្រោក ។



កណ្ដុរនឹងឆ្មា

ឆ្មាឈ្មោលឆ្មាញី សត្វឆ្មាទាំងពីរ រកស៊ី
តែយប់ ដេកថ្ងៃស្ងៀមស្ងាត់ ពួននៅបន្ទប់
វាក្រោកពេលយប់ ដេញខាំកណ្ដុរ សត្វ
នេះឯងអាច ជាសត្វកំណាច ចិត្តវាជា
ចោរ តែងលួចបំផ្លាញ ច្រឹប-កាត់អាវ-ខោ
រឿងសត្វកណ្ដុរ មានចៃកើតប៉េស្ដ ។

អក្សរផ្ចង់

ឆាបឆក់ ស្ទុតឆាប់ ទោមលើត




ជញ្ជីង ទុកថ្លឹង សម្រាប់ឲ្យដឹង ទម្ងន់ប៉ុន្មាន
បើគ្មានជញ្ជីង នោះនឹងលើកស្ទាន ខូច·
ការពុំខាន ពុំបានរាបស្មើ ។ អ្នកប្រាជ្ញ
ជាន់ចាស់ គេរាប់អានណាស់ ទុកជាប្រ·
សើរ គេទុកជាផ្លូវ ឲ្យចៅក្រមដើរ
ចៅក្រម ទុកប្រើ លុះដល់ សព្វថ្ងៃ

ជួបជិតបានជាប់ បើបង់ក្តីគាប់ នឹងគ្រូអាចារ្យ
កាន់ចិត្តស្លូតត្រង់ ហើយត្រូវឧស្សាហ៍ ព្យាយាមខាង
ការរៀនសូត្រកុំខ្ជិល ។

អក្សរផ្ចង់

ជំនួរ ជំនាយ ជ័យជោគ ជាជាន



ឈូសឈើ

ដែកឈូសត្រូវខ្នាត គេឈូសឈើ
ស្អាតប្រដាប់ប្រដា សំរាប់ជាងឈើ
ធ្វើស្អាតដោយសារ ជាងឈើត្រូវការ
ពុំដែលខានឡើយ ។

អក្សរផ្ចង់

ឈប់ឈឹង ឈោងឈាន ឈូសឈើ



ឈ្លូស

សត្វឈ្លូសនេះណា ប្អូកជា សត្វរូប-
ប៉ុនសត្វឆ្កែ មានស្នែងជាខ្លី នៅព្រៃស្រុក-
ខ្មែរ ពួកព្រានពូកែ ឆ្លុះបាញ់បានងាយ។

ឈ្លូសឈើធ្វើការ ជាងឈើឧស្សាហ៍ រិះគិតតុប
តែង ធ្វើទូតុតាំង ធ្វើផ្ទះសម្បែង ខំគិតខ្នងឯង
ឲ្យបានត្រូវខាត ។

# ញ



ញញួរ

ប្រដាប់ ញញួរ ប្រើការតាមគួរ ជា
គ្រឿងចំណាប់ ខាងវាយដែកគោល ធ្វើ
ការបានឆាប់ គ្រឿងនេះសំរាប់ ដកចេញ
ក៏បាន ។

ញាតិញោមញញឹម ដោយមានសង្ឃឹម លើកូនជ្រះថ្លា ខាងផ្លូវរៀនសូត្រ ខិតខំឧស្សាហ៍ ហេតុនោះមាតា បិតាអរណាស់ ។

អក្សរផ្ចង់

ញាតិញោម ញញឹម ញឹកញយ



ដំរី

ដំរីធំណាស់ សត្វចេះអៀនខ្មាស ជា
ជាងសត្វឯង. ចាញ់កល មនុស្សលោក
មកជាប់ចំណង [១] សង់ផ្ទះលើខ្នង ជិះ
បានច្រើនគ្នា។

---

១ សង់ផ្ទះលើខ្នង “គឺកែញ៉ងដំរី ឬ កូបដំរី ,



ដើមដូង

ដើមដូងគេដាំ ធ្វើជាដំណាំ ផ្លែធ្វើ
អាហារ មានដាំដោយស្រុកនៅស្រែចំការ
គេដាំដីណា ដែលមានដង្ហើមទឹក ។

អក្សរផ្តង់

ដាំ ដូង ដុះហាល ដូចដើម



ដង្កូវនាង

ដង្កូវនាងណុក ចេះធ្វើសំបុក បិទជិតអាត្មា ជាន់ចាស់រកឃើញ ចេះថែរក្សា ចាស់មានប្រាជ្ញា ដាក់មុងដេកចាំ ។ ថ្នាក់ថ្នមពេកក្ដាត់ ដោយក្ដីប្រយ័ត្ន កុំឲ្យមុសខាំ កុំឲ្យវាក្ស័យ សព្វថ្ងៃគេចាំ ស្រាវសូត្ររាល់ឆ្នាំ ធ្វើជាព្រែហូល ។

# អក្សរ ឋ នឹង ឱ

មានពាក្យប្រើតិច ឋាន ឋិត, ឋិត ថេរ

ឱម - ឱន, ឱ - ឱ្យ,



ណែន ណាន់នេះណា សំរាប់ ប្រើការ

ចន់ កក្របី មួយ ណាកំណាច មិនបេះ

ប្រណើ ដេញវ័ធក្របី ណាខ្សោយជាន់វា ។

អក្សរផ្ចង់

ណែនណាន់ ណែលណោល់ ណោះណោះ



៣

តុតាំងជាគ្រឿង ប្រដាប់រុនរៀន នៅគេ
ហដ្ឋាន តុនេះឯងណា បើការដាក់បាន
សរសេរក៏បាន ស្រួលល្មមដូចចិត្ត

គាត់តែងជាប្រាប់ ឲ្យក្មេងរៀនឆាប់ សំរើបចិន្តា
ឲ្យមានពាក្យជូន ក្មេងតែងត្រូវការ កើតក្តីជ្រះថ្លា
ឧស្សាហ៍រៀនសូត្រ ។



តាវៅនឹងក្អែក

តាវៅនឹងក្អែក ស្លាបវាខ្មៅប្លែក ពី
សត្វធម្មតា ស៊ីតែសត្វស្លាប់ ធ្វើជាអាហារ
បីដូចអាចារ្យ ទាស់តែធ្វើចោរ ។

ឮពាក្យចាស់ថា សត្វមានសាវតារ ជាសត្វអាក្រក់ តាវៅខ្ឋនតួប វាហ៊ានលួចឆក់ ចិត្តវាអាក្រក់ លួចពងក្អែកស៊ី ។



តោ

សត្វតោនេះណា មាឌធំជាងខ្លា សំ
បើមពេកក្ដាត់តែងមានអំណាច លើសលប់
អស់សត្វនៅទីព្រៃស្ងាត់ សត្វផងដោះដៃ ។
ស្រុកខ្មែរគ្មានតោ មានខ្លានឹងចោរ ពួន
ព្រៃសព្វថ្ងៃ អ្នកដើរកាត់ព្រៃ ជួនគ្រោះដល់
ក្ស័យព្រៃណាសង្ស័យ កុំដើរកាត់ឡើយ ។

អក្សរផ្ចង់

តាម តឿន តាក់តែង តាំងតួ



(ចាស)

ប្រយោជន៍នៃចាស អ្នកឯងស្គាល់
ច្បាស់ សម្រាប់ទ្រចាន គេត្រូវការ
ណាស់ ចាស់តែងទាប់អាន បើមាន
បុណ្យទាន ទូលចាសទៅវត្ត ។

ឲ្យ ថ្លែង ថែង ការ ទុក ឲ្យ កុមារ រិះ រៀន ជា ច្បាប់ ចាស់ ទុក ជា ប្បង អ្នក ផង ត្រង ត្រាប់ បៀស ក្ដី ឪន អាប់ ត្រូវ ខំ សិក្សា ។ ខ្ពស់ ឯក មារ យាទ បេះ ការ ពារ ជាតិ ដោយ បេតនា ពុំ ត្រូវ អ្នក ខ្ជិល រក ស៊ី ធ្វើ ការ នឹង ខំ សិក្សា ព្យាយាម ជានិច្ច ។

អក្សរផ្ចង់

ចា ចាង ចាន ចិត ចែម ចៃយ



ទន្សាយ

ទន្សាយ នេះណា បេត្ត មានសាវតារ.
អាថ៌ការកាត់ក្តី គេឆ្លាក់រូបវា ទុកជា.
ប្រក្រតី ទៅត្រាមន្ត្រី កាត់ក្តីនោះឯង ។



ទី ទុយ នេះ ណា
ស៊ី ជា អា ហារ
សុទ្ធ សឹង ក្តាម ខ្យង
រកស៊ីតែ យប់ ចៀសក្តីសោហ្មង ដោយ
ក្អែក ចាំ ចង គុំគួនបន្ទា ។



ទុង ទា

សត្វទុងនឹងទា ជើងជាប់ដូចគ្នា ឆ្អឹង ទុងសំប៉ែត វាស្រាលជាងទា ខ្លួនវាអណ្តែត លើទឹកជាហេតុ ឲ្យសំគាល់បាន ។

អក្សរផ្ចង់

ទាក់ទង ទល់ទ័ព ទៀងទាត់



ធុង

ធុងជាប្រដាប់ គេទុកសម្រាប់ ធ្វើការ
នានា ដាក់ស្រា អង្ករ បានល្អ ដូចគ្នា
ពុំនោះ ទុក វា ដាក់ទឹក ក៏បាន ។

ធូរ ធារ ធន ធាន ធ្វើ ជា អ្នក មាន លុះ ដោយ មារយាទ បេះ បាយ សំបៃ សន្សំ មួយ ជាតិ ស្មោះ ត្រង់ ដល់ ញាតិ ជិត ខាង ធម្មតា ។ កាន់ ឫក សុភាព ដាក់ ខ្លួន ឲ្យ ទាប កាន់ ចិត្ត មេត្តា កាល មាន បុណ្យ ដ៉ាន រាប់ អាន ស្នេហា ជួយ ដោយ ជ្រះ ថ្លា ជិ រាប ជិត ខាន ។

អក្សរផ្ចង់

ធន ធាន ធុង ធំ ធូរ ធារ



ស្តីពីនាឡិកា មានគ្រប់
អាត្មា ជាការគប្បី វា
ចេះប្រាប់ម៉ោង វេលា
រាត្រី ពេលថ្ងៃចេះស្តី
ឲ្យយើងស្តាប់បាន ។

នាឡិកា



នំ

នំនៅពេញថាស ក្មេងចូលចិត្តណាស់ ដោយផ្អែមពិសា បំណាំឆ្ងាញ់ឈ្ងុយ ជានុយកុមារ ទុកឲ្យកូនណាឱស្សាហ៍រៀនសូត្រ ។

អក្សរផ្ចង់

នាងនេះ នែបនិត្យ នៅនា



នាគ

រូប នាគ នេះ ណា មាន ក្នុង សាវតារ ព្រួស ទឹក កើត ភ្លើង ឃើញ តែ តំនូរ គ្មាន នាគ ស្រុក យើង ព្រួស ទឹក កើត ភ្លើង ឃើញ តាម សាវតារ ។

យើង បាន ពិនិត្យ ចង់ យក ក្ដី ពិត ពុំ បាន ច្បាស់ ការណ៍ ព្រោះ គ្មាន នាគ រស់ នៅ ក្នុង លោក មាន តែ សាវតារ បុរាណ សម័យ ។



ប្រវឹក

ប្រវឹកព្រវែក នៅដោយបឹងព្រែក
មានហ្វូងត្រៀបត្រា ប្រឹងព្រួតចាប់ត្រី ធ្វើ
ជាអាហារ រូបវានេះណា ដូចទាចំទន់ ។

ក្មេងប្រឹងអាត្មា ពុំទាន់ដឹងការ ដែលក្មេងនៅល្ងង់
ឃើញសត្វប្រវឹក ហែលទឹកកំពង់ ក្មេងនៅឆោតល្ងង់
ប្រឡំថាទា ។



បង្កើត ត្បាល់ បុក
ទម្លាប់ អ្នក ស្រុក
បុក ស្រូវ ដង្រុក
អង្កាម គេ បោល
អង្ករ គេ ទុក បុក
ស ដូច ភ្នុក ទុក
ធ្វើ អា ហារ ។

បុត្តព្យងប្រាប់ថា មាតា
បិតា លោកគ្មានគិត
ស្ដាយ រឿងសង្គ្រោះបុត្ត
បរិសុទ្ធឥតក្លាយ ត្រូវប្អូនទាំងឡាយ កុំក្លាយភ្លេចគុណ ។

អក្សរជ្រុង

បំបួស បានបុណ្យ ឱបាច់ បានបែប



ផើង

ផ្តិល កើតជាផើង. មាត់ធំ សាច់ស្តើង
សម្រាប់ ប្រើការ បានគ្រប់បែបយ៉ាង តាម
ចិត្តប្រាថ្នា រូបផើងនេះណា ប្រើការច្រើន
មុខ ។

ផុតផែនផ្លូវផង់ រៀនបេះព្រោះបង់ រៀនត្រង់ព្រោះគ្រូ បង់បៀសផ្លូវល្ងង់ ត្រូវរៀនគិតគូរ រៀនបេះដោយធ្ងូរ ព្រោះគ្រូហ៊ឹកហ្វឺន ។

អក្សរផ្ចង់

ផិត ផុត ផុយ ផាយ ផ្ទូវ ផាវ



ពីងពាងខ្លួនខ្មាញ់ ធ្វើជាសំណាញ់
ចិញ្ចឹមអាត្មា ស៊ីសត្វតូចៗ ធ្វើជាអា-
ហារ ស៊ីតែសត្វណា ជាប់សំណាញ់វា

ពាក្យពិតវែងស្លែង បញ្ឈោរនោះឯង គេតែងត្រូវការ ម៉ុនស្ដី ត្រូវគិត កុំផ្ដិលវាចា រើសរកពាក្យណា ឲ្យល្មមសមស្ដី ។ កាប ផ្ដិលនឹងប្លស់ ពោលពាក្យមិនស្មោះ បំពោះប្រុសស្រី កាយ វាចាចិត្ត មិនដោយគប្បី នឹងអាប់សេរី ដោយពាក្យទ្រគោះ ។ ទោះទំងក្ដីណា ត្រូវកាន់វាចា ស្រទន់ពិរោះ កុំឆាប់ក្រោធក្រេវ កុំឆាប់ប្រឈ្លោះ កុំពាក្យប្រជ្រួស នាំអាប់ផល់ប្រាណ ។



ពង្រូល

ពង្រូលលាក់មុខ គួរឲ្យចាំទុក ប្លែក
សត្វធម្មតា កាលជួបព្រានព្រៃ រួញលាក់
ភក្ត្រា គ្មានរត់ទៅណា ឲ្យព្រានចាប់បាន
ក្មេងណាលាក់មុខ គ្រូបានទាយទុក ថា
ពុំចំណាន ប៊ីដូចពង្រូល គេចាប់ពុំខាន
ចូរសិស្សគ្រប់ប្រាណ កុំលាក់មុខឡើយ ។

អក្សរផ្ចង់

ពាក្យ ពិត ពិស ពាក់ ពេញ ពាស



ភេ

ស្ដីពីសត្វភេ គួរឲ្យគិតគ្រោះ ប្លែក
ភ្លាំងអស្ចារ្យ គ្មានគួរនឹងជុះ កាលបើ
ត្រូវការ រកើ អាហារ- ចាស់ចេញតាម
មាត់ ។

ភរភូតកុហក វាចាអាក្រក់ ភូតបាញ់អាត្មា ពាក្យភូតឲ្យផល
ដល់រូបអ្នកណា ហោកទាបអស្ចារ្យ ព្រោះពាក្យក្លែងក្លាយ ។
ភុំភឿនភូមិភព បើនឹងសេពគប់ ត្រូវគិតវែងឆ្ងាយ មិត្តអប្ប
លក្ខណ៍ កុំអ្នកសហាយ កុំបង់សប្បាយ ប្រយ័ត្នប្លស់ប្រាណ។

អក្សរផ្ចង់

ភុំ ភឿន ភូមិ ភព ភិន ភាគ



មួក

មួកសមានវណ្ណ សំពត់ច្រើនជាន់
គ្របលើសិរសា បាំងកំដៅថ្ងៃ អ្នកខ្លះ
ត្រូវការ ពាក់ជាធម្មតា ពុំសូវដែលខាន ។



មាន់

មាន់ញីមាន់គក ប្រមូលគ្នាមក រកស៊ី
ទាំងហ្វូង មានកន្ទុយខ្លី គេហៅកណ្ដុង
កកាយដីខ្លះ រិះរកអាហារ ។



មូស

ពិសមូសមានរោគ មានច្រើនក្នុង
លោក ឆ្លងរោគគ្រុនចាញ់ រោគក្តៅញ័រញាក់
ស៊ីអ្វីមិនឆ្ងាញ់ ជម្ងឺគ្រុនចាញ់ គ្រុនលស់
យូរឆ្នាំ ។ ការពារអាត្មា បើដើរទៅណា
កុំឲ្យមូសខាំ ដេកមុងឲ្យជិត ត្រចៀកឲ្យចាំ
ផឹកទឹកត្រូវដាំ ឲ្យឆ្អិនដរាប ។

មុខមាត់មាំមួន ឫកពាធឹងធ្ងួន កិរិយារម្យទម មារយាទ ហ្មត់ហ្មង អ្នកផងនិយម គាប់ចិត្តចាស់ទុំ ប្រសើរពេកក្តាត់ ។

អក្សរផ្ចង់

មើល មុខ មាំ មួន មុត មែន



យន្ត

យន្តតូចដេរដៃ ក្មេងមានដៃថ្លៃ ជិះ
ជួយ ចំណាប់ ជារបស់ចំណាន ញានការ
ឆ្លុត ឆាប់ ទុកជាប្រដាប់ សំរាប់ដេរផាស់

យាយតារីករាយ ឃើញកូនចៅងាយ រៀនបេះ រហ័ស ដើរលឿនរហូត តាមដានបាស់ៗ ម៉ែឪអរណាស់ ឃើញបេះដូបបិត្ត ។

អក្សរផ្ចង់

យានយាស យោធយិត យោគយល់



រៃ

ខ្លួនតូចដូចរៃ រស់នៅក្នុងព្រៃ សត្វមាន
សាវតារ សំឡេងពុខ្លាំង លើសលុបអាត្មា
មានពាក្យចាស់ថា សំឡេងដូចរៃ ។

រិះរករីករាយ ពុំត្រូវមើលងាយ និស្សិតឧស្សាហ៍ មុខ
រៀនទំខែង តែងកើតបញ្ញា ទុកជួយរក្សា រដ្ឋឯករាជ្យ ។

អក្សរផ្ចង់

រុករាន រៀបរៀង រាងទៅ



រមាស

រមាសនេះណា ស៊ីតែបន្លា ផឹកទឹក
ល្អក់ខាប់ វាខាំកូនឈើ ដាច់ដូចគេកាប់
គេចោមសម្លាប់ យកមកធ្វើថ្នាំ ។ ប្រើការ
សាកល អាចម៍វាមិនសល់ ចិនសែបានផ្ដាំ
កែរោគចំណាន បានកត់ចំណាំ សត្វនេះ
រឆកម្ម អារឹះពេកក្លាត់ ។



លលក

រីសត្វលលក គេចាប់
បានមក ថ្នាក់ថ្នម ឥត
ហ្មង ផ្សាំងផ្សើរផ្នាក់
ទាក់ យក ពួក ជន
ដោយចេះឆ្លើយឆ្លង
ប្រឈ្លោះដល់គ្នា ។



លា

ចំណែក
សត្វលា
សត្វនេះពិត
ជាសុភាព
រាបសា មិនកាចដូចសេះ ដែលចេះក្លៀវក្លា
សត្វលានេះណា មុខគួរអាណិត ។



ល្វាចេក

ល្វាចេកនេះណា   សត្វមានភាសា
ស្ប្យសៀងភិរម្យ   សំឡេងពីរោះ   អ្នកផង
និយម   មានទោសប៉ុនភ្នំ   ព្រោះសៀង
វាថា ដាប់ទ្រូងតែឯង ចាកពីកន្លែង ឃ្លាត
ឆ្ងាយសង្សារ ព្រួយចិត្តរាល់ថ្ងៃ ស្ទើក្ស័យ
ជីវា   ទោសកើតដោយសារ   គេចោម
ស្រឡាញ់ ។



តាមគំនិតគ្រូ តុបតែងជារូ ឲ្យក្មេងកុំ
សាន្តជាគ្រឿងសប្បាយ ឲ្យក្មេងលេងបាន
ចូលចិត្តគ្រប់ប្រាណ គ្មានគ្រោះថ្នាក់អ្វី ។

វក់វីវវឹក ត្រូវក្រោកពីព្រឹក រៀបចំខ្លួនប្រាណ ទៅរៀនសាលា ជាការបំណាន បើក្មេងណាខាន ពុំបានរៀនក្តី ៗ ក្មេងនោះគ្មានយស កេរ្តិ៍ពុំពីរោះ ឈ្មោះគ្មានឮល្បី ព្រោះគ្មានបំណោះ មិនចេះធ្វើអ្វី ញាតិទាំងប្រុសស្រី ពុំភក្តីឡើយ ៗ

អក្សរផ្ចង់

ភាសភាង ភាស់វៃង ភាលទង់



សេះ

សត្វសេះប្រើបាន ចំណាប់ចំណាន បានខាង

រហ័ស ធ្វើជាជំនិះ បានការស្រួលណាស់

អ្នកផងស្គាល់ច្បាស់ ជាសត្វរត់លឿន ។

ស្រណោះសាលា កាលខ្ញុំសិក្សា ភ្លេចឃ្លានបាយទឹក ដល់ពេលឈប់រៀន ទើបខ្ញុំភ្ញាក់នឹក ញាំរពោះគ្រឹកៗ ព្រោះឃ្លានអាហារ ។ ខ្ញុំដើររហ័ស ព្រោះឃ្លានបាយណាស់ នឹកដល់មាតា លោកចាំមើលផ្លូវ ដោយក្ដីស្នេហា ព្រមទាំងបិតា អង្គុយចាំបាយ ។



សេក

សេក សត្វ បក្សា  សត្វ មាន សារតារ

ទុក ជាប្រក្រតី សេកសោមបណ្ឌិត្យ សម្បុរ

ខៀវខ្ចី ឈ្លាស ខាង ចង់ស្រី ក្រមុំសារិកា ។

អក្សរផ្ចង់

សាមសិប សេកសោម សាកសួរ



ហ៊ឹង

ស្ដីពី សត្វហ៊ឹង ស្បែកវារលិង កំ-
ប៉ោង ធំគក់ គេចាប់ហ៊ឹងជា គេ
ចោលហ៊ឹងជីរ អ្នកមានអ្នកក្រ-ស៊ី
ជាអាហារ ។



វ៉ាលីស៍

វ៉ាលីស៍ហិបស្បែក ធ្វើបានល្អប្លែក រាងសម
ត្រាន់បើ ប្រើការបានស្រួល ខាងធ្វើដំណើរ
ឃើញគាប់ប្រសើរ ដាងវេចសំពាយ ។

អក្សរផ្ចង់

ហាសហាយ ហិចហោះ ហៅហាន



ឡុកឡាក

ឡុកឡាក់ ចាំច្បាស់ បណ្តាំពាក្យ
ចាស់ ហាមប្រាមគ្រប់គ្នា មិនឲ្យបៀត
បៀន រៀនល្បែងពាលា អាក្រក់ពុំ
ជា មិនឲ្យដើរដិត ។

ឡុកឡាយប្រឡំ ប្រឡោតមិនសម ខ្លះជាចិត្តខ្លាំង ខ្លះជាចិត្តឈ្លើយ មិនចេះលោកបាំង អាចហ៊ានប្រឆាំង នឹងអ្នកមានគុណ ។

អក្សរផ្ចង់

ឡឹក ឡក់ ឡុកឡាក់ ឡាយឡុង



អាវកុង

អាវកុងខ្មៀវក ដៃវែងពណ៌
ស គ្រឿងបិទបាំងកាយ ប្រើបាន
គ្រប់គ្នា ជាសុខសប្បាយ អ្នកខ្លះ
កែក្លាយ ខ្លី-វែង គ្រប់បែប ។

អំពិលអំពែក ទំមែកឫស្សី ក្មេងទាំងប្រុសស្រី ព្រួតរៀនវិជ្ជា ។

អំពិលអំពែក ទំមែកពុទ្រា យើងត្រូវព្រួតគ្នា ទ្រទ្រង់សាសនា ។

អំពិលអំពែក ទំមែកចម្ប៉ា ប្រឹងគ្រប់អាត្មា រក្សាឯករាជ្យ ។



អណ្ដើក

អណ្ដើក មាន ស្នូក កំប៉ោង កំប៉ុក ដើរ ខ្លី ខ្វៃៗ ឡើង គោក ពេល យប់ មុជ ទឹក ពេល ថ្ងៃ ពង លក់ បាន ថ្លៃ អាស្រ័យ នៅ បាន ។ មាន ពាក្យ ចាស់ ថា លួច លាក់ នាំ ការណ៍ អាក្រក់ សា មាន្យ ធ្វើ មេ អណ្ដើក ជាប់ ចោទ ពុំ ខាន ស៊ី អ្វី ពុំ បាន ហៅ មាត់ អណ្ដើក ។

អក្សរផ្ចង់

[illegible]

បទកាកគតិ

ទុំលុះទុំណាយ សំពត់សំពាយ សំពៅសំពោង សំប៉ាន
សំប៉ែត អណ្តែតឃ្លេងឃ្លោង ឃរឃានដៃឃោង ចាប់ចង
នៃបនិត្យ ។ សំពៅទៅមុខ សំប៉ានគេទុក ប្រើការជិតៗ
បំឡងជ្លួបស្ដាន អ្នកមានគំនិត សំប៉ានគេគិត ជំនួយ
សំពៅ ។ បើពោលនឹងខាន មិនរាប់សំប៉ាន អាងបាន
ទឹកជ្រៅ លុះដល់ទឹករាក់ អ្នកបង់ឆ្លងទៅ កាន់ទីលំនៅ
ពិតពុំ បានឡើយ ។

បទកាកគតិ

ហៃអស់កុមារ ប្រឹងគ្រប់អាត្មា កុំខិលកុំខូប ត្រូវខំ
រៀនសូត្រ ទាន់ខ្លួននៅតូច សម្រាំងសម្រួប បំណេះប្រាជ្ញា ។
បើកូនណាខ្ជិល ពុំបង់រមិល ខាងផ្លូវសិក្សា វែងវង់ទុក្ខសោក
ដល់ចាស់ជរា ឲយហោកមហិមា នឹងប្រៀបពុំបាន ។
ពេលនេះត្រូវខំ ត្រូវកូនសន្សំ បំណេះបំណាន រៀនសូត្រ
ត្រូវប្រុង ស្ដាប់គ្រូឲ្យបាន ប្រដៅប៉ុន្មាន ចូរអានកុំភ្លេច ។

ហៃកូនប្រុសស្រី កើតនាលោកិយ គ្រប់ប្រាណ គ្មានសល់ ខ្ញុំសូមរំឭក អ្នកតាមយោបល ខ្ញុំមកពុំដល់ ប្រាប់ផ្ទាល់ពុំបាន ។ ហេតុនេះខ្ញុំតែង ជាក្បួនមិនវែង ជាច្បាប់បំណាន ខ្ញុំធ្វើបែបខ្លី ស្ដីតាមលំអាន ទុកដាក់តាមដ្ឋាន ដែលខ្ញុំបានយល់ ។ សូមអស់កុមារ ខិតខំសិក្សា រៀនសូត្ររៀងរាល់ ប្រាណប្រុសស្រីប្រឹង រំពឹងខ្វាយខ្វល់ ជិតឆ្ងាយកុំធ្វល់ នឹងពាក្យទូន្មាន ។ ខ្ញុំបង់ឲ្យល្អ អិនបង់ឲ្យក្រ បង់ឲ្យអ្នកមាន បំណេះវិជ្ជា គ្រប់គ្នាជាយាន ជាផ្លូវជាស្ពាន ទុកសម្រាប់ឆ្លង ។

មាតាបិតា ត្រេកអរអស្ចារ្យ ដោយឃើញបុត្រប្យង បេះបៃរក្សា មិនឲ្យមានហ្មង ដល់ប្អូនតូចផង ស្នងឪពុកម្ដាយ ។ កូននោះទឹងប្ដើង បុណ្យស័ក្តិនឹងឡើង ល្បីនាមសុះសាយ អ្នកជិតភក្ដី[១] មេត្រីអ្នកឆ្ងាយ ញាតិផងទាំងឡាយ ស្រឡាញ់គ្រប់ប្រាណ ។

---

១ ភក្ដី “សេចក្ដីស្រឡាញ់ស្មោះ, សេចក្ដីស្លូតត្រង់, សេចក្ដីគោរព” ។

ខ្លួនខ្ញុំធំល្មម ចិត្តខ្ញុំក៏ព្រម ទៅរៀនសាលា ឲ្យគ្រូ
ស្រឡាញ់ ត្រូវខ្ញុំឧស្សាហ៍ គាប់ចិត្តមាតា បិតានៃខ្ញុំ ។

---

កាលខ្ញុំនៅតូច របុលរប៉ូច ពុំទាន់ដឹងក្ដី នៅផ្ទះមិនសុខ
ខ្ញុំប៉ប៉ុកដី បងខ្ញុំប្រុសស្រី ជួយថែរក្សា ។ ខ្ញុំនៅចាំច្បាស់
ដល់ខ្លួនខ្ញុំចាស់ មានបានកាលណា ខ្ញុំនឹងសងគុណ ឲ្យពេញ
ចិត្តា ចង់ខាតយ៉ាងណា ខ្ញុំគ្មានស្ដាយឡើយ ។

---

ខ្ញុំនៅសាលា ខំប្រឹងសិក្សា ភ្លេចឃ្លានបាយទឹក
ដល់ពេលឈប់រៀន ទើបខ្ញុំភ្នកនឹក ញ័រពោះគ្រឹក ៗ
ព្រោះឃ្លានអាហារ ។ ខ្ញុំដើររហ័ស ព្រោះឃ្លានបាយណាស់
នឹកដល់មាតា លោកចាំមើលផ្លូវ ដោយក្ដីស្នេហា ព្រមទាំង
បិតា អង្គុយចាំបាយ ។

ខ្ញុំចាំកលកិច្ច កាលខ្ញុំបេះតិច គ្រូប្រឹងប្រាប់ប្រែង ខ្ញុំរៀនមិនចាំ ជួនកាលបែកខ្នង ខ្ញុំគិតច្រើនផង បង់គេចនៅផ្ទះ ។ ដោយខ្ញុំស៊ូទ្រាំ ទាំងចិត្តឲ្យមាំ ដោយក្ដីជំនះ ខ្ញុំរៀនយប់ថ្ងៃ ដែលខ្ញុំសំពះ រំឭកគុណព្រះ ឲ្យជួយគាំពារ ។ ខ្ញុំរៀនបានយូរ ទើបស្គាល់គុណគ្រូ ច្រើនមហិមា ថ្លៃជាងមាសពេជ្រ ទ្រព្យធននានា ប្តើងផ្សិតវិជ្ជា ស្ងួនភ្ជាមារយាទ ។

ខ្ញុំព្រួយកអនេក[1] ចិត្តខ្ញុំសង្វេគ អាស្សូរដល់ជាតិ រលឹកដល់ស្រុក ដែលខ្ញុំចាកឃ្លាត រលឹកដល់ញាតិ ដែលបាត់មុខយូរ ។ ដើមទ្រូងខ្ញុំតឹង ដកដង្ហើមប្រឹង ខ្យល់ខ្លាំងព្យូរ បញ្ចើមខ្ញុំបង មុខខ្ញុំឡើងជូរ នឹកដល់គុណគ្រូ អាចារ្យសាកល ។ មាតាបិតា គិតខ្លាំងអស្ចារ្យ សំអាង-មគ្គផល ត្រិះរិះជញ្ជឹង រំពឹងខ្វាយខ្វល់ ដោះស្រាយក្ដីឆ្ងល់ ឲ្យផុតសង្ស័យ ។ អំពីឃ្លាតកាយ នៅដោយឋានឆ្ងាយ យូរខែយូរថ្ងៃ ព្រោះបង់បេះដឹង ប្រឹងកាត់អាល័យ យកអនាម័យ[2] ថ្ងៃព្រោះវិជ្ជា ។

---

១ អនេក; មិនមែនតែមួយ គឺច្រើន ។

២ អនាម័យ; ការមិនមានរោគ បានដល់សេចក្ដីសុខសប្បាយ (មន្ទីរការពាររោគ) ។

## ពាក្យ ៧

គុណគ្រូមិនធូរមិនថយឆ្ងាយ នឹងឪពុកម្តាយបង្កើតមុន គុណគ្រូមិនស្រាលពេញជាធ្ងន់ ត្រូវគន់គិតមើលក្នុងចិត្តា អ្នកមួយមានពូជអ្នកមួយដាំ យូរឆ្នាំទើបបានផលផ្លែផ្កា គុណគ្រូត្រូវសងដោយជ្រះថ្លា ទុកស្មើបិតា កុំធុញថប់ បានតិចជូនតិចឥតបើអ្វី ទោះនំចំណីរៀបកញ្ចប់ ជូនគ្រូឪម៉ែឲ្យគ្រប់សព្វ កំណប់បុណ្យថ្ងៃឡើងតបគុណ សិនបើតាជូនកូននៅឡើយ កូនអើយត្រូវគិតខាងណោះមុន ដោយប្រាណតាជូនកូនចាស់ស៊ិន នឹងធនរស់យូរពុំបានឡើយ បើអ្នកភ្លេចគុណដូចភ្លេចគិត គំនិតកន្តួបចិត្តកន្តើយ ទេព្តាពុំស្បិតឃើញចិត្តស្បើយ ម៉ោះហើយខ្មោចព្រាយហ៊ានយាយី សត្រូវចូលជិតហ៊ានយុកយាក់ ខ្លួនអ្នកមានព្រួយខ្លាំងដល់ទី ខាតខានពុំសូវបានរកស៊ី សត្រូវញាំញីពុំមានល្ហៃ ឃើញល្មមប្រឈមឲ្យឈ្មោះល្មឹល ទេព្តាមិនខ្វិលកត់ស្បែកថ្កែ អំពីកូនភ្លេចគុណឪម៉ែ អាងខ្លួនពូកែមានទ្រព្យធ្ងន់ អាងបេះពូកែមានបុណ្យខ្ពស់ អាងយសអាងសក្តិមកដាក់ខ្លួន សំដីយើងថ្លោសឲ្យខុសក្បួន ខ្មែរចិនសៀមយួនប្រើសព្វថ្ងៃ ។

ភ្នំពេញថ្ងៃ ១៥ កើត ខែចេត្រ (១៣ មេសា ១៩៤៩)

កូនកុំវាយពស់ទៅឲ្យក្អែក កុំហែកកេរ្តិ៍ញាតិទៅប្រាប់ព្រៀង
ដូចយកអំបិលទៅហាលភៀង ដូចកៀងជាតិឯងទំលាក់ទឹក ។
កូនកុំមើលងាយសត្វខ្លាស្គម អន់ទ្រមនៅស្ងៀមកុំយល់ស្ដឹក
កាលសាប់ពេញពោះនឹងផ្លាស់ប្រក ធ្វើឲ្យអ្នកភ្លឹកវិញពុំទាន ។

បើបាបានបុណ្យត្រូវបេះបង់ កុំដើរកន្លងផ្លូវសុចរិត ប្រាជ្ញ
ប្រាយនៅឆ្ងាយហៅមកជិត នោះបារឹងរឹតមានរស្មី ។ បើ
ពោលអ្នកបេះធ្វេសទៅចាប់ យកស្លូតអាងស្លាប់ធ្វើមេត្រី ចាស់
ផ្ដាំឲ្យប្រើអ្នកបេះក្ដី ទើបបានសួស្ដីមកបិតកាយ ។

ភ្នំពេញថ្ងៃទី ១៨ វិច្ឆ គ. ស. ១៩៥០

ក្នុង ១ អាទិត្យមាន ៧ ថ្ងៃ គឺ:

១ – អាទិត្យ
២ – ចន្ទ
៣ – អង្គារ
៤ – ពុធ
៥ – ព្រហស្បត៍
៦ – សុក្រ
៧ – សៅរ៍

## បែបរៀនរាប់ទិស

*យើងត្រូវបង្រៀន វិជ្ជាដែលគប្បីឲ្យក្មេងចេះជាដំបូងអំពីទិសមាន ៨*




១ – ឧត្តរ (ឯជើងត្រង់)
២ – ឦសាន (ជ្រុងឯកើត)
៣ – បូព៌ (ឯកើតត្រង់)
៤ – អាគ្នេយ៍ (ជ្រុងឯត្បូង)
៥ – ទក្សិណ (ឯត្បូងត្រង់)
៦ – និរតី (ជ្រុងឯលិច)
៧ – បស្ចិម (ឯលិចត្រង់)
៨ ពាយ័ព្យ (ជ្រុងឯជើង)

# របៀបរៀនរាប់ខែ

ក្នុង ១ ឆ្នាំ មាន ១២ ខែ ។ នៅប្រទេសខ្មែរការប្រើខែមានកំណត់ ជា ២ យ៉ាង គឺខែចន្ទគតិ ១ ខែសុរិយគតិ ១ ។

ខែចន្ទគតិ ក្នុងឆ្នាំធម្មតា មាន ២៩ ថ្ងៃចំនួន ៦ ខែ. និង ៣០ ថ្ងៃចំនួន ៦ ខែ ។ តែបើឆ្នាំដែលមានអធិកវារៈ ខែដែលមាន ២៩ ថ្ងៃចំនួន ៥ ខែ និងមាន ៣០ ថ្ងៃចំនួន ៧ ខែ ។ បើឆ្នាំដែលមានអធិកមាសវិញ ខែមាន ២៩ ថ្ងៃចំនួន ៦ ខែដូចឆ្នាំធម្មតា, ប៉ុន្តែមាន ៣០ ថ្ងៃចំនួន ៧ ខែដូចឆ្នាំដែលមានអធិកវារៈដែរ ។ ឆ្នាំណាមានអធិកមាស ឆ្នាំនោះត្រូវមានខែ ១៣ ខែ ។

ខែសុរិយគតិ មាន ២៨ ឬ ២៩ ថ្ងៃចំនួ ១ ខែ មាន ៣០ ថ្ងៃចំនួន ៤ ខែនិង ៣១ ថ្ងៃចំនួន ៧ ខែ ។ ឈ្មោះខែតាមចន្ទគតិនិងសុរិយគតិ ដូចមាននៅទំព័រ ៧៩ ។

## ខែចន្ទគតិ

ខែខ្មែរ

| | | |
|---|---|---|
| ១ – មិគសិរ | ២៩ | ថ្ងៃ |
| ២ – បុស្ស | ៣០ | – |
| ៣ – មាឃ | ២៩ | – |
| ៤ – ផល្គុន | ៣០ | – |
| ៥ – ចេត្រ | ២៩ | – |
| ៦ – ពិសាខ | ៣០ | – |
| ៧ – ជេស្ឋ | ២៩ឬ៣០ | – |
| ៨ – អាសាឍ | ៣០ | – |
| ៩ – ស្រាពណ៍ | ២៩ | – |
| ១០ – ភទ្របទ | ៣០ | – |
| ១១ – អស្សុជ | ២៩ | – |
| ១២ – កត្តិក | ៣០ | – |

## ខែសុរិយគតិ

ខែខ្មែរ និង ខែបារាំង

| | | | |
|---|---|---|---|
| ១ – មករា | យ៉ាំងវីយេរ | ៣០ | ថ្ងៃ |
| ២ – កុម្ភៈ | ហ្វេវ្រីយេរ | ២៨ ឬ ២៩ | – |
| ៣ – មីនា | ម៉ារ្ស | ៣១ | – |
| ៤ – មេសា | អាវ្រិល | ៣០ | – |
| ៥ – ឧសភា | ម៉េ | ៣១ | – |
| ៦ – មិថុនា | យូអាំង | ៣០ | – |
| ៧ – កក្កដា | ស៊ុយយេត | ៣១ | – |
| ៨ – សីហា | អាអ៊ូតឬអ៊ូត | ៣១ | – |
| ៩ – កញ្ញា | សេបតម្ប្រ័ | ៣០ | – |
| ១០ – តុលា | អុកតូប្រ័ | ៣១ | – |
| ១១ – វិច្ឆិកា | ណូវ៉ែមប្រ័ | ៣០ | – |
| ១២ – ធ្នូ | ដេសម្ប្រ័ | ៣១ | – |

បុណ្ណមីព្រះចន្ទ និស្សិតសំខាន់ បេះបង់បាច់គ្នា បានជាកម្លាំង សម្រាប់ ការពារ ក្រុងកម្ពុជា ឲ្យមានសួស្តី ៗ ជនជាតិខេមរៈ ខិតខំពេញវគ្គ ទាំងប្រុសទាំងស្រី តូចធំចាស់ក្មេង នៅក្នុងបុរី ព្រួតគ្នាមេត្រី ដល់ជាតិ មាតុភូមិ ៗ

# បែបរៀនរាប់ឆ្នាំ

ចំនួន ១២ ខែហៅថា ១ ឆ្នាំ ៗ ក្នុង ១ ឆ្នាំ, បើគិតតាមខែចន្ទគតិ[១] មាន ៣៥៤ ថ្ងៃចំពោះឆ្នាំធម្មតា និង ៣៥៥ ថ្ងៃចំពោះឆ្នាំដែលមានអធិកវារៈ ៗ បើឆ្នាំណាមានអធិកមាស ខែលើកថែម ឆ្នាំនោះមាន ៣៨៤ ថ្ងៃ ៗ គឺលើកត្រង់ខែអាសាឍជា ២ ដង, មុនហៅ បឋមាសាឍ (អាសាឍទី ១) ក្រោយហៅ ទុតិយាសាឍ (អាសាឍទី ២) សុទ្ធតែមាន ៣០ ថ្ងៃដូចគ្នា បើគិតតាមខែសុរិយគតិ[១] ក្នុង ១ ឆ្នាំមាន ៣៦៥ ខ្លះ ៣៦៦ ថ្ងៃខ្លះ ៗ

## ឈ្មោះឆ្នាំទាំង ១២

| | |
|---|---|
| ១ – ជូត | ៧ – មមី |
| ២ – ឆ្លូវ | ៨ – មមែ |
| ៣ – ខាល | ៩ – វក |
| ៤ – ថោះ | ១០ – រកា |
| ៥ – រោង | ១១ – ច |
| ៦ – ម្សាញ់ | ១២ – កុរ |

---

១ ចន្ទគតិ គិតតាមព្រះចន្ទ ។

២ សុរិយគតិ គិតតាមព្រះអាទិត្យ ។

រោងពុម្ពអាល្បែរពរតែ ភ. ព.